# នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស និងខ្មែរ

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 09-Sep-2016, 14:57
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

# សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំសេចក្ដីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្ដារា

ចៅក្រម Claudia FENZ

Original EN:

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**មេធាវីប្រចាំការ៖**

ទូច វរល័ក្ស

Calvin SAUNDERS

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE
Patrick BAUDOUIN
Beini Ye

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមស្នើសេចក្តីបញ្ជាក់អំពីស្ថានភាពនៃបទចោទដែលសេសសល់នៅក្នុងសំណុំរឿង០០២ រួមមាន បទចោទទាក់ទងនឹងមន្ទីរសន្តិសុខសង់ មន្ទីរសន្តិសុខកោះខ្យង មន្ទីរសន្តិសុខព្រៃដំរីស្រុត ទីកន្លែងសម្លាប់មនុស្សនៅក្នុងស្រុក១២ មន្ទីរសន្តិសុខវត្តគិរីរម្យ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខគោកក្តួច មន្ទីរសន្តិសុខវត្តធ្លក កន្លែងសម្លាប់មនុស្សនៅស្ទឹងតូច ការដ្ឋានព្រៃស ការដ្ឋានស្រែអំបិល ការប្រព្រឹត្តលើពុទ្ធសាសនិក (ទូទាំងប្រទេស) ការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី៣ និងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជានៅលើទឹកដីវៀតណាម។

## II. ច្បាប់ជាធរមាន

2. វិធាន ២១ (១) ចែងថា ជនរងគ្រោះទទួលបានប្រយោជន៍ពី "សច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ។ លើសពីនេះ វិធាន ២១ (១) (គ) ចែងថា "អង្គជំនុំជម្រះវិសាមញ្ញត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"។

3. វិធាន៨៩ ស្ទួនពីរ ចែងថា "នៅពេលប្រយោជន៍យុត្តិធម៌តម្រូវ នៅដំណាក់កាលណាមួយ អង្គជំនុំជម្រះសាលាដំបូង អាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ រឿងក្តីដែលត្រូវបានបំបែក ត្រូវយកមកជំនុំជម្រះ និងវិនិច្ឆ័យចេញសាលក្រមទៅតាមលំដាប់លំដោយដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាសមស្រប"។

4. វិធាន៨៩ ស្ទួនបី ចែងថា៖

> ១. ដើម្បីធានាបាននូវកិច្ចដំណើរការនីតិវិធីមួយប្រកបដោយយុត្តិធម៌ អត្ថន័យ និងឆាប់រហ័ស ជាពិសេសដោយពិចារណាលើលក្ខខណ្ឌតម្រូវជាក់លាក់នៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូង អាចសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះ ដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅ

ជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងត្រូវធានាថា អង្គហេតុដែលនៅសល់ត្រូវយកជាតំណាង ចំពោះវិសាលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ។

២. មុនពេលដកអង្គហេតុចេញពីវិសាលភាពនៃការជំនុំជម្រះ អង្គជំនុំជម្រះត្រូវស្តាប់ការលើកឡើងរបស់ភាគីនីមួយៗ។

៣. អង្គជំនុំជម្រះសាលាដំបូងត្រូវបញ្ចប់កិច្ចដំណើរការនីតិវិធី ពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ។ នៅពេលដែល សេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃការជំនុំជម្រះចូលជាស្ថាពរ អង្គហេតុដែលត្រូវបានដកចេញ នឹងមិនអាចត្រូវបានប្រើជាមូលដ្ឋានសម្រាប់ដំណើរការនីតិវិធីប្រឆាំងនឹងជនជាប់ចោទដដែលនោះបានឡើយ។ ភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវបានដកចេញ អាចត្រូវបានប្រើប្រាស់ ក្នុងករណីដែលភស្តុតាងទាំងនោះពាក់ព័ន្ធនឹងអង្គហេតុដែលនៅសល់ផ្សេងទៀត។

៤. សេចក្តីសម្រេចកាត់បន្ថយវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសមាសភាពនៃបណ្តុំដើមបណ្តឹងរដ្ឋប្បវេណីឡើយ។

5. បន្ទាប់ពីការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២[1] អង្គជំនុំជំនុំជម្រះតុលាការកំពូល បានព្យួរជាបណ្តោះអាសន្ននូវបទចោទនៅក្រៅវិសាលភាពសំណុំរឿង០០២/០១ និងសំណុំរឿង ០០២/០២ ដោយសំអាងថា៖

> ...ការគ្រប់គ្រងសំណុំរឿងយ៉ាងទូលំទូលាយតម្រូវឲ្យបង្កើតផែនការច្បាស់លាស់សម្រាប់ការជំនុំជម្រះលើបទចោទទាំងមូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងរំលឹកថាពុំមានផ្នែកនៃកិច្ចដំណើរការនីតិវិធីណា អាចត្រូវបានទុកចោល "ក្នុងភាពមិនប្រាកដប្រជា" នោះឡើយ។ ផ្ទុយទៅវិញ រាល់បទចោទទាំងអស់ដែលជាលទ្ធផលនៃការបំបែកត្រូវធ្វើការដោះស្រាយ មានន័យថាត្រូវទទួលបានការជំនុំជម្រះលើអង្គសេចក្តី ត្រូវទទួលបានការព្យួរ ឬត្រូវទទួលបានការបដិសេធចោល។ ដោយពិចារណាឃើញនូវកង្វះនៃលទ្ធភាពក្នុងការ

[1] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ **E301/9/1** ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤។

រៀបចំបទចោទសម្រាប់ការជំនុំជម្រះនាពេលអនាគតដែលប្រមើលមើលបាន អាស្រ័យហេតុនេះ អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា កិច្ចដំណើរការនីតិវិធីដែលពុំទាន់បានជំនុំជម្រះទាក់ទងនឹងបទចោទដែលនៅសេសសល់ក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង០០២/០២ ត្រូវព្យួរជាផ្លូវការ។ សេចក្តីប្រកាសអំពីស្ថានភាពនៃកិច្ចដំណើរការនីតិវិធីនេះ គ្រាន់តែបម្រើដល់គោលបំណងនៃតម្លាភាព ដោយប្រកាសនូវអ្វីដែល*តាមព្រឹត្តិហេតុ* ត្រូវបានធ្វើចាប់តាំងពីការចាប់ផ្តើមការជំនុំជម្រះក្នុងសំណុំរឿង ០០២។ កិច្ចដំណើរការនីតិវិធីទាក់ទងនឹងបទចោទ ដែលនៅសេសសល់ អាចត្រូវបានបន្តទាំងស្រុង ឬដោយផ្នែក នៅពេលលទ្ធភាពនៃការជំនុំជម្រះលើអង្គសេចក្តី ឬការសម្រេចជាក់លាក់ដទៃទៀត អាចកើតមាន[2]។

## III. សារណា

6. នៅពេលសំណុំរឿង០០២/០២ បានមកដល់ដំណាក់កាលចុងក្រោយនៃការជំនុំជម្រះ សហមេធាវីនាំមុខ កត់សម្គាល់អំពីកង្វះព័ត៌មានច្បាស់លាស់ទាក់ទងនឹងបទចោទនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២។ នៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែម អង្គជំនុំជម្រះសាលាដំបូង ពុំបានដោះស្រាយបញ្ហានៃការដកចេញបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយឡើយ ដោយកត់សម្គាល់ថាអង្គជំនុំជម្រះសាលាដំបូង "ពុំចាំបាច់ដោះស្រាយបញ្ហានេះក្នុងដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះទេ"[3]។
វិសោធនកម្មលើកទី៩នៃផែនការបញ្ចប់របស់ អ.វ.ត.ក ("ផែនការបញ្ចប់") បង្ហាញថាសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០២ នឹងត្រូវបញ្ចប់ ក្នុងអំឡុងត្រីមាសចុងក្រោយក្នុងឆ្នាំ ២០១៦[4]។ ផែនការបញ្ចប់ ក៏លើកឡើងអំពីបទចោទដែលនៅសេសសល់ និងការចោទប្រកាន់លើអង្គហេតុ ដោយសន្និដ្ឋានថា "មកដល់ពេលបច្ចុប្បន្ន អង្គជំនុំជម្រះ

[2] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1/1/3** ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤ កថាខណ្ឌ៨៩។

[3] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ **E301/9/1** ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ កថាខណ្ឌ៤៥។

[4] ផែនការបញ្ចប់ អ.វ.ត.ក, កែសម្រួលលើកទី ៩ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៨ (https://www.eccc.gov.kh/sites/default/files/Completion%20Plan-Final-Rev9%20.pdf, released 20 July 2016).

ពុំទាន់ទទួលសំណើណាមួយទាក់ទងនឹងបញ្ហានេះទេ។ បញ្ហានេះកំពុងត្រូវបានពិចារណា”[5]។ យោងទៅលើការលើកឡើងខាងលើនេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយល់ឃើញថាវាជាពេលសមស្រប ដើម្បីពិនិត្យ លើបទចោទនានាដែលនៅសេសសល់ក្នុងសំណុំរឿង០០២។

7. សហមេធាវីនាំមុខសូមរំលឹកជូនថា ដើមបណ្តឹងរដ្ឋប្បវេណីសរុបចំនួន ៤៤៦នាក់ ត្រូវបានទទួលស្គាល់ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ថាជាជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោលនៃទង្វើដែលជាលទ្ធផលនៃបទចោទដែលស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង ០០២/០១ និង០០២/០២។ បទចោទទាំងនេះទាក់ទងនឹងមន្ទីរសន្តិសុខសង់ មន្ទីរសន្តិសុខ កោះខ្យង មន្ទីរសន្តិសុខព្រៃដំរីស្រុត ទីកន្លែងសម្លាប់មនុស្សនៅក្នុងស្រុក១២ មន្ទីរសន្តិសុខ វត្តគិរីរម្យ មន្ទីរសន្តិសុខភូមិភាគឧត្តរ មន្ទីរសន្តិសុខគោកក្តួច មន្ទីរសន្តិសុខវត្តធ្លក កន្លែងសម្លាប់មនុស្សនៅស្ទឹងតូច ការដ្ឋានព្រៃស ការដ្ឋានស្រែអំបិល ការប្រព្រឹត្តលើពុទ្ធសាសនិក (ទូទាំង ប្រទេស) ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី៣ និងឧក្រិដ្ឋកម្មប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជានៅលើទឹកដីវៀតណាម។

8. សហមេធាវីនាំមុខមានការពាក់ព័ន្ធជាពិសេស ដោយពិចារណាលើកាតព្វកិច្ចជាវិជ្ជមានរបស់ខ្លួនក្នុងការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីអំពីស្ថានភាពនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានក្លាយជាភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះចាប់តាំងពីឆ្នាំ ២០០៧ និងមានសិទ្ធិទទួលបានសច្ចភាពផ្លូវច្បាប់ និងទទួលបានការជូនដំណឹងទាក់ទងនឹងបទចោទទាំងអស់នៅក្នុងសំណុំរឿង០០២ ជាពិសេស ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៤៦ នាក់ ដែលបានរងផលប៉ះពាល់ដោយផ្ទាល់ពីស្ថានភាពនៃបទចោទដែលនៅសេសសល់។

9. អាស្រ័យហេតុនេះ មេធាវីនាំមុខ ស្នើសុំឲ្យចេញនូវផែនការការងារមួយ ដែលផ្តល់ព័ត៌មានច្បាស់លាស់ទាក់ទងនឹងបទចោទដែលសេសសល់ក្នុងសំណុំរឿង ០០២ និងផ្តល់សិទ្ធិឲ្យភាគីទាំងអស់បញ្ចេញមតិយោបល់។

## IV. សំណើ

10. សហមេធាវីនាំមុខ សូមស្នើដោយក្តីគោរពជូនអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

---

[5] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ៤៥។

(១) ចេញផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្ញើជូនទៅដល់ភាគី

(២) ផ្តល់សេចក្តីបញ្ជាក់ ឬព័ត៌មានបន្ថែមពាក់ព័ន្ធនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ដើម្បីឲ្យសហមេធាវីនាំមុខអាចបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីដោយអនុលោមតាមវិធានផ្ទៃក្នុង។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |